ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ... សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ... ឆ្នាំ២០១៣

# ប្រកាស

## ស្តីពី

## ការប្រមូលពន្ធប្រថាប់ត្រា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ១១.នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣៣០/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធប្រថាប់ត្រា



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សេចក្តីសម្រេច

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់បែបបទ និងនីតិវិធីប្រមូលពន្ធប្រថាប់ត្រារបស់រដ្ឋបាលសារពើពន្ធ ស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដើម្បីពង្រឹងការគ្រប់គ្រងប្រមូលពន្ធ និងបង់ចូលក្នុងគណនីទោលនៃរតនាគារជាតិ ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការអភិវឌ្ឍមូលដ្ឋាន ។

### ប្រការ ២.- វត្ថុធាតុនៃពន្ធ

ផ្អែកតាមជំពូកទី៣ ផ្នែកទី១ ដែលចែងពីបទប្បញ្ញត្តិមួយចំនួនស្តីពីពន្ធប្រថាប់ត្រា នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ពន្ធប្រថាប់ត្រាត្រូវបានប្រមូលចំពោះ ៖

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន និងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន
- កិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្ត ជាអាទិ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុន បញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន ។

### ប្រការ ៣.- អ្នកទទួលបន្ទុកបង់ពន្ធ

ពន្ធប្រថាប់ត្រាត្រូវប្រមូលពី ៖

- អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬមធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុន
- អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- អ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្ត ។

### ប្រការ ៤.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ ៖

១. ពាក្យ "ញាតិ" សំដៅដល់ ៖

- រវាងឪពុកម្តាយបង្កើត និងកូនបង្កើត
- រវាងប្តី និងប្រពន្ធ
- រវាងបងប្អូនបង្កើត និងបងប្អូនបង្កើត
- រវាងឪពុកម្តាយក្មេក និងកូនប្រសារ
- រវាងយាយតាបង្កើត និងចៅបង្កើត ។

២. ពាក្យ "តម្លៃចុះកិច្ចសន្យា" សំដៅដល់តម្លៃលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ ។

៣. ពាក្យ "តម្លៃភាគហ៊ុន" សំដៅដល់តម្លៃនៃការផ្ទេរភាគហ៊ុន ផ្អែកតាមតម្លៃទីផ្សារ ។

៤. ពាក្យ "ថវិការដ្ឋ" សំដៅដល់ថវិកាជាតិ ឬថវិកាថ្នាក់ក្រោមជាតិ ដែលមានចែងនៅក្នុងហិរញ្ញវត្ថុច្បាប់ប្រចាំឆ្នាំនីមួយៗ ។

៥. ពាក្យ "ទំនិញ ឬសេវា" សំដៅដល់ទំនិញ សំណង់ ឬសេវា ។

៦. ពាក្យ "ប្រទានកម្ម" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សរស់ទៅឱ្យញាតិដោយមិនយកថ្លៃ ។

៧. ពាក្យ "ប្រធានសក្តិ" សំដៅដល់ហេតុភូត ឬព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចពាក់ព្រាងទុកជាមុនបាន និងមិនអាចជំនះបាន ដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី) សង្គ្រាម កុប្បកម្ម អគ្គិភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ ។

៨. ពាក្យ "ភាគហ៊ុន" សំដៅដល់ចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬផលប្រយោជន៍ ឬបេក់អាជីវកម្មរបស់ក្រុមហ៊ុននីតិបុគ្គល ក្រុមអាជីវកម្ម និងសហគ្រាសឯកបុគ្គល ដែលបានចុះបញ្ជី ឬមិនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ។

៩. ពាក្យ "មធ្យោបាយដឹកជញ្ជូនឬយានយន្ត" សំដៅដល់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដូចជា រថយន្ត ម៉ូតូ ទូក កាណូត កប៉ាល់ សាឡាង... ដែលបានចុះបញ្ជី ឬមិនចុះបញ្ជី ដោយស្ថាប័នសាធារណការនិងដឹកជញ្ជូន ។

១០. ពាក្យ "លិខិតមានលក្ខណៈគតិយុត្តិ" សំដៅដល់លិខិតមានលក្ខណៈគតិយុត្តិស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ។

១១. ពាក្យ "សន្តតិកម្ម" សំដៅដល់ការផ្ទេរអចលនទ្រព្យពីមនុស្សស្លាប់ទៅឱ្យញាតិ តាមរយៈ ÷

- បណ្តាំជាលាយលក្ខណ៍អក្សរ ករណីគ្មានទំនាស់ ឬ
- បញ្ជាក់លើលិខិតយថាភូត ករណីគ្មានទំនាស់ ឬ
- សាលក្រម ឬសាលដីកាតុលាការ ករណីមានទំនាស់ ។

១២. ពាក្យ "អចលនទ្រព្យ" សំដៅដល់ដី ផ្ទះ អគារ និងសំណង់ផ្សេងៗ ទោះបីបានចុះបញ្ជី ឬមិនបានចុះបញ្ជី ដោយរដ្ឋបាលសុរិយោដី ។

## ប្រការ ៥.- ការលើកលែងពន្ធ និងអនុគ្រោះពន្ធ

ក. ការលើកលែងពន្ធ

ពន្ធប្រថាប់ត្រាត្រូវបានលើកលែង ដូចខាងក្រោម ÷

១. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល សម្រាប់ជាប្រយោជន៍សេដ្ឋកិច្ច ឬសង្គមកិច្ច ពីដីឯកជនរបស់រដ្ឋដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់សង់លំនៅដ្ឋាន ឬ/និងធ្វើកសិឧស្សាហកម្ម ឬកសិកម្មជាលក្ខណៈគ្រួសារ ។

២. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ដែលត្រូវតក់ត្រាចុះក្នុងបញ្ជីសារពើភ័ណ្ឌរបស់ស្ថាប័ននានានៃព្រះរាជាណាចក្រកម្ពុជា ។

៣. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្តរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

៤. ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសនានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធ-អាករប្រចាំខែ និងប្រចាំឆ្នាំ ។ ដោយឡែក ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ដែលបានចុះបញ្ជីនៅស្ថាប័នសាធារណការនិងដឹកជញ្ជូន មិនត្រូវបានលើកលែងពន្ធប្រថាប់ត្រានេះទេ ។

៥. អ្នកវិនិយោគមូលបត្រដែលទទួលសិទ្ធិកាន់កាប់ភាគហ៊ុនតាមរយៈការផ្តល់ជូនមូលបត្រក្នុងទីផ្សារដំបូង ឬក្នុងទីផ្សារបន្ទាប់ ។

ការផ្ទេរភាគហ៊ុន ការទទួលសិទ្ធិកាន់កាប់ភាគហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការកែប្រែរចនាសម្ព័ន្ធភាគហ៊ុនិក ដូចជា ការបំបែកភាគហ៊ុន (Share split) របស់ក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងទីផ្សារដំបូង ឬនៅក្នុងទីផ្សារបន្ទាប់ ឬក្រុមហ៊ុនដែលធ្វើអាជីវកម្មពាក់ព័ន្ធក្នុងវិស័យមូលបត្រ ទោះបីតម្រូវឱ្យមានការកែប្រែលក្ខន្តិកៈក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្មក៏ដោយ ការលើកលែងពន្ធប្រថាប់ត្រានេះត្រូវមានលិខិតបញ្ជាក់ពីគណៈកម្មការមូលបត្រកម្ពុជា ។

ករណីក្រុមហ៊ុនមិនអាចធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈបាន ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អ្នកទទួលសិទ្ធិកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុននេះត្រូវជាប់ពន្ធប្រថាប់ត្រា និងត្រូវទូទាត់ពន្ធប្រថាប់ត្រានៃការផ្ទេរភាគហ៊ុនកន្លងមក ដោយអនុលោមតាមប្រកាសនេះ លើកលែងតែមានលិខិតបញ្ជាក់ដោយឡែកពីគណៈកម្មការមូលបត្រកម្ពុជាដោយផ្អែកលើមូលហេតុសមស្រប ដូចជា ករណីប្រធានសក្តិជាដើម ។

ខ. ការអនុគ្រោះពន្ធ

ពន្ធប្រថាប់ត្រា ត្រូវបានអនុគ្រោះចំពោះការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យពីញាតិ ដោយអនុញ្ញាតឱ្យដកចេញពីតម្លៃជាមូលដ្ឋានគិតពន្ធចំនួន ៖

- ២០០.០០០.០០០ រៀល (ពីររយលានរៀល) ចំពោះសន្តតិកម្ម
- ១០០.០០០.០០០ រៀល (មួយរយលានរៀល) ចំពោះប្រទានកម្ម

ការអនុគ្រោះខាងលើ ត្រូវមានឯកសារជាភស្តុតាងបញ្ជាក់អំពីញាតិ ដូចជា សៀវភៅគ្រួសារ សំបុត្រកំណើត សំបុត្រអាពាហ៍-ពិពាហ៍ និង/ឬឯកសារផ្សេងទៀត ដែលអាចបញ្ជាក់ទំនាក់ទំនងរវាងបុគ្គលមានចែងក្នុងកថាខណ្ឌ ១ នៃប្រការ ៤ ខាងលើ ។

<u>ឧទាហរណ៍ទី១</u>

លោក "ក" មានដី និងផ្ទះ តាមតម្លៃទីផ្សារ ២១០.០០០.០០០ រៀល ។ មុនពេលគាត់ស្លាប់បានធ្វើបណ្តាំទៅកូន (សន្តតិកម្ម) ។

ដូចនេះ ពន្ធប្រថាប់ត្រាត្រូវបង់គឺ ៖

(២១០.០០០.០០០ រៀល - ២០០.០០០.០០០ រៀល) X ៤% = ៤០០.០០០ រៀល

ក្នុងករណីតម្លៃដី និងផ្ទះនេះត្រឹមក្រោម ២០០.០០០.០០០ រៀល ការផ្ទេរនេះមិនជាប់ពន្ធទេ ។

ក្នុងករណីលោក "ក" ចែកដី និងផ្ទះ ទៅកូន ២នាក់ ស្មើៗគ្នា ដោយកូននីមួយៗទទួលបាន ១០៥.០០០.០០០ រៀល ។ ដូចនេះ តម្លៃទ្រព្យរបស់កូននីមួយៗ ក្រោមតម្លៃ ២០០.០០០.០០០ រៀល មិនត្រូវជាប់ពន្ធទេ ។

<u>ឧទាហរណ៍ទី២</u>

លោក "ក" បានឱ្យដី និងផ្ទះ ទៅលោក "ខ" ជាប្អូនបង្កើត ជាអំណោយដោយមិនគិតថ្លៃ (ប្រទានកម្ម) ។ តាមតម្លៃទីផ្សារដី និងផ្ទះនេះ មានតម្លៃ ២១០.០០០.០០០ រៀល ។

ដូចនេះ ពន្ធប្រថាប់ត្រាត្រូវបង់គឺ ៖

(២១០.០០០.០០០ រៀល - ១០០.០០០.០០០ រៀល) X ៤% = ៤.៤០០.០០០ រៀល

ក្នុងករណីតម្លៃដី និងផ្ទះនេះស្មើ ឬក្រោម ១០០.០០០.០០០ រៀល ការផ្ទេរនេះមិនជាប់ពន្ធទេ ។

ក្នុងករណីលោក "ក" លក់ដី និងផ្ទះនេះទៅឱ្យលោក "ខ" ដែលជាប្អូនបង្កើតនោះ ត្រូវជាប់ពន្ធប្រថាប់ត្រាតាមមូលដ្ឋានគិតពន្ធធម្មតា (មិនទទួលការអនុគ្រោះពន្ធទេ) គឺ ៖

២១០.០០០.០០០ រៀល X ៤% = ៨.៤០០.០០០ រៀល

## ប្រការ ៦.- អត្រាពន្ធ និងការកំណត់ពន្ធ

អត្រាពន្ធ និងការកំណត់ពន្ធប្រថាប់ត្រា មានដូចខាងក្រោម ÷

១. ៤% នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ ឬ/និងដី ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន ។

២. ៤% នៃតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្ត ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ ។

៣. 0,១% នៃតម្លៃភាគហ៊ុន ចំពោះការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុន ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

៤. 0,១% នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ ។

៥. ១.000.000 រៀល (មួយលានរៀល) ចំពោះលិខិតមានលក្ខណៈគតិយុត្ត ៣ប្រភេទគឺ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការបិទក្រុមហ៊ុន និងលិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា (រួមទាំងលិខិតរំលាយក្រុមហ៊ុនបញ្ចូលគ្នារបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រសាធារណៈ ដូចមានចែងក្នុងកថាខណ្ឌនេះ) ។

## ប្រការ ៧.- តម្លៃជាមូលដ្ឋានសម្រាប់គិតពន្ធ

តម្លៃជាមូលដ្ឋានសម្រាប់គិតពន្ធប្រថាប់ត្រាត្រូវបានកំណត់ ដូចខាងក្រោម ÷

១. អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត ត្រូវគិតតាមតម្លៃទីផ្សារនាពេលផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់តម្លៃអចលនទ្រព្យ និងតម្លៃមធ្យោបាយដឹកជញ្ជូនឬយានយន្ត សម្រាប់ធ្វើជាមូលដ្ឋានគិតពន្ធនេះ ។

២. ភាគហ៊ុន ត្រូវគិតតាមតម្លៃទីផ្សារនាពេលប្រតិបត្តិការផ្ទេរភាគហ៊ុននោះកើតឡើង ។

៣. កិច្ចសន្យា ត្រូវគិតតាមតម្លៃក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា ។

៤. លិខិតមានលក្ខណៈគតិយុត្ត ត្រូវកំណត់ ១.000.000 រៀល (មួយលានរៀល) ចំពោះលិខិតមានលក្ខណៈគតិយុត្តនីមួយៗ ។

## ប្រការ ៨.- កាតព្វកិច្ចអ្នកជាប់ពន្ធ

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប្រថាប់ត្រា ឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ៣ខែ ÷

១. ចំពោះអចលនទ្រព្យ បន្ទាប់ពីការសម្រេចនៃកំណត់បង្ហាញរបស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីរាជធានី-ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ។

២. ចំពោះមធ្យោបាយដឹកជញ្ជូនឬយានយន្ត បន្ទាប់ពីថ្ងៃចុះហត្ថលេខារបស់អ្នកទទួលសិទ្ធិលើសំណុំឯកសារ "ពាក្យសុំផ្ទេរកម្មសិទ្ធិយានយន្ត" របស់មន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី-ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរកម្មសិទ្ធិ ។

៣. ចំពោះភាគហ៊ុន បន្ទាប់ពីប្រតិបត្តិការផ្ទេរភាគហ៊ុនកើតឡើង ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងការផ្ទេរភាគហ៊ុន ។

៤. ចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា បន្ទាប់ពីកាលបរិច្ឆេទនៃកិច្ចសន្យា ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងកិច្ចសន្យានេះ ។

៥. ចំពោះលិខិតមានលក្ខណៈគតិយុត្តិ បន្ទាប់ពីការសម្រេចរបស់ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនឹងលិខិតនេះ ។

ការជាប់ពន្ធ ការលើកលែងពន្ធ ឬការអនុគ្រោះពន្ធទាំងអស់ ត្រូវយកមកប្រថាប់ត្រានៅរដ្ឋបាលសារពើពន្ធ លើកលែងតែ ÷

- ការផ្ទេរ ឬការទទួលសិទ្ធិកាន់កាប់ភាគហ៊ុនពាក់ព័ន្ធនឹងវិស័យមូលបត្រ ដូចមានចែងក្នុងកថាខណ្ឌ ៥ នៃប្រការ ៥ នៃប្រកាសនេះ
- ការទិញមធ្យោបាយដឹកជញ្ជូនឬយានយន្ត ធ្វើជាទំនិញដើម្បីលក់វិញរបស់សហគ្រាសធានា ដែលបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ និងបានបង់ពន្ធ-អាករប្រចាំខែ និងប្រចាំឆ្នាំ ដូចមានចែងក្នុងកថាខណ្ឌ ៤ នៃប្រការ ៥ នៃប្រកាសនេះ ។

## ប្រការ ៩.- ទោសប្បញ្ញត្តិ

១. អ្នកទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមធ្យោបាយដឹកជញ្ជូនឬយានយន្ត អ្នកទទួលចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវា អ្នកទទួលសិទ្ធិលើភាគហ៊ុន និងអ្នកទទួលសិទ្ធិលើលិខិតមានលក្ខណៈគតិយុត្តិ អនុលោមតាមប្រកាសនេះ ដែលមិនបានបង់ពន្ធប្រថាប់ត្រាទាន់ពេលវេលាកំណត់ដូចមានចែងក្នុងប្រការ ៨ ត្រូវពិន័យស្មើនឹងចំនួនប្រាក់ពន្ធប្រថាប់ត្រាដែលត្រូវបង់ ។

២. ប្រសិនបើម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ថ្មីនោះ មិនបានបង់ពន្ធប្រថាប់ត្រា ÷

- ហាមរដ្ឋបាលសុរិយោដី ផ្តល់វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យថ្មីនោះ
- ហាមស្ថាប័នសាធារណការនិងដឹកជញ្ជូន ផ្តល់ប័ណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូនឬយានយន្តថ្មីនោះ។

## ប្រការ ១០.- ការអនុវត្តប្រកាស

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.នាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលារាជធានី-ខេត្ត
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋាន/សាខា ______________

# លិខិតប្រកាស
# ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ

## I. ព័ត៌មានកម្មសិទ្ធិករ

| 01 បរិយាយ | ឈ្មោះ | ភេទ | អាយុ/ឆ្នាំ | លេខលិខិតសម្គាល់ខ្លួន (១) | អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់អចលនទ្រព្យ | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផ្ទះលេខ | ផ្លូវ | ភូមិ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | ខេត្ត/រាជធានី |
| អ្នកផ្ទេរសិទ្ធិ | | | | | | | | | | |
| អ្នកទទួលសិទ្ធិ | | | | | | | | | | |
| ទូរស័ព្ទអ្នកទទួលសិទ្ធិ: | | | | | សារអេឡិចត្រូនិក (E-mail) អ្នកទទួលសិទ្ធិ: | | | | | |

(១)- សូមគូសក្នុងប្រអប់ ☐ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ☐ សំបុត្របញ្ជាក់កំណើត ☐ សៀវភៅគ្រួសារ ☐ សៀវភៅស្នាក់នៅ ☐ លិខិតបញ្ជាក់ទីលំនៅ ☐ លិខិតឆ្លងដែនសម្រាប់ជនបរទេស

## II. ព័ត៌មានអចលនទ្រព្យ

- ឯកសារសម្គាល់អចលនទ្រព្យ : លិខិតលេខ ______________ ចុះថ្ងៃទី ____ ខែ ______ ឆ្នាំ ______ ចេញដោយ ______________
- អាសយដ្ឋានអចលនទ្រព្យ : លេខ ________ ផ្លូវ ____________ ភូមិ ______________ ឃុំ/សង្កាត់ ______________
ក្រុង/ស្រុក/ខណ្ឌ ______________ ខេត្ត/រាជធានី ______________ ។
- រូបភាពផ្ទេរសិទ្ធិ : ☐ទិញ ☐ អំណោយ ☐ ដោះដូរ
- ប្រភេទអចលនទ្រព្យ : ១- ☐ ដី ២- ☐ សំណង់:
  - ☐ បេតុង (☐ ផ្ទះ ☐ អគារ)
  - ☐ មិនមែនបេតុង (☐ ផ្ទះ ☐ អគារ)
  - ☐ ខុនដូ

## III. ការគណនាប្រាក់ពន្ធ

| 02 បរិយាយអចលនទ្រព្យ | ដី / សំណង់ | | | | | តម្លៃអចលនទ្រព្យ |
|---|---|---|---|---|---|---|
| | អាយុកាលសំណង់ | | ជាន់ទី(២) | ទំហំ (ម²) | តម្លៃ/ម² | |
| | ដល់១០ឆ្នាំ | លើស១០ឆ្នាំ | | | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 = 5 x 6 |
| ១- ដី | | | | | | |
| ២- សំណង់ : | | | | | | |
| - ជាន់ក្រោមដី | | | | | | |
| ជាន់ផ្ទាល់ដី | | | | | | |
| - ជាន់ទី១ | | | | | | |
| - ជាន់ទី២ - ទី៥ | | | | | | |
| - ជាន់ទី៦ - ទី១០ | | | | | | |
| - ចាប់ពីជាន់ទី១១ ឡើងទៅ | | | | | | |
| តម្លៃសរុប | | | | | | |
| ☐ អនុញ្ញាតឱ្យដក ១០០,០០០,០០០រៀល ចំពោះប្រមានកម្ម | | | | | | |
| ☐ អនុញ្ញាតឱ្យដក ២០០,០០០,០០០រៀល ចំពោះសន្តតិកម្ម | | | | | | |
| មូលដ្ឋានគិតពន្ធ | | | | | | |
| ប្រាក់ពន្ធត្រូវបង់ = មូលដ្ឋានគិតពន្ធ x ៤% | | | | | | |

(២)- សម្រាប់សំណង់ ចំពោះជាន់ទី២ដល់ទី៥ ជាន់ទី៦ដល់ទី១០ និង ចាប់ពីជាន់ទី១១ ឡើងទៅ ត្រូវគិតរួមបញ្ចូលគ្នាទាំងជាន់ និងទំហំ ។

ខ្ញុំបាទ-នាងខ្ញុំសូមធានាថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះពិតជាត្រឹមត្រូវ និងសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។

**សម្រាប់មន្ត្រីពន្ធដារ**

របៀបនៃការបង់ប្រាក់ : ☐សាច់ប្រាក់ ☐មូលប្បទានប័ត្រ ☐ផ្សេងៗ
ចំនួនទឹកប្រាក់ ..............................
បង្កាន់ដៃបង់ប្រាក់លេខ ........................ ចុះថ្ងៃទី ...../...../.....
[illegible] ........................ [illegible] ...../...../.....
ឈ្មោះមន្ត្រីពន្ធដារ ........................ ហត្ថលេខា ........................

ធ្វើនៅ______________, ថ្ងៃទី ______ ខែ ______ ឆ្នាំ ________

ហត្ថលេខា ឬស្នាមមេដៃស្តាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋាន/សាខា______________

# លិខិតប្រកាស
## ពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់
## មធ្យោបាយដឹកជញ្ជូន ឬយានយន្តគ្រប់ប្រភេទ

### I. ព័ត៌មានកម្មសិទ្ធិករ

| បរិយាយ | ឈ្មោះ | ភេទ | អាយុ/ឆ្នាំ | លេខលិខិតសម្គាល់ខ្លួន(១) | អាសយដ្ឋានបច្ចុប្បន្នរបស់ម្ចាស់អចលនទ្រព្យ | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផ្ទះលេខ | ផ្លូវ | ភូមិ | ឃុំ/សង្កាត់ | ក្រុង/ស្រុក/ខណ្ឌ | ខេត្ត/រាជធានី |
| អ្នកផ្ទេរសិទ្ធិ | | | | | | | | | | |
| អ្នកទទួលសិទ្ធិ | | | | | | | | | | |
| ទូរស័ព្ទអ្នកទទួលសិទ្ធិ: | | | | | សារអេឡិចត្រូនិក (E-mail) អ្នកទទួលសិទ្ធិ: | | | | | |

(១)- សូមគូសក្នុងប្រអប់ ☐ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ☐ សំបុត្របញ្ជាក់កំណើត ☐ សៀវភៅគ្រួសារ ☐ សៀវភៅស្នាក់នៅ ☐ លិខិតបញ្ជាក់ទីលំនៅ ☐ លិខិតឆ្លងដែនសម្រាប់ជនបរទេស

### II. ព័ត៌មានមធ្យោបាយដឹកជញ្ជូន ឬយានយន្ត

- ឯកសារសម្គាល់មធ្យោបាយដឹកជញ្ជូន ឬយានយន្ត ៖ លិខិតលេខ______________ ចុះថ្ងៃទី______ ខែ______ ឆ្នាំ______

ចេញដោយ______________________________

- រូបភាពទទួលសិទ្ធិកាន់កាប់៖ ☐ ទិញ ☐ អំណោយ ☐ ដោះដូរ
- ប្រភេទ៖ ☐ រថយន្តទេសចរណ៍ ☐ រថយន្តដឹកទំនិញ ☐ រថយន្តដឹកអ្នកដំណើរ ☐ រ៉ឺម៉កសណ្តោងរថយន្ត
  ☐ ទោចក្រយានយន្ត ☐ ត្រីចក្រយានយន្ត ☐ រ៉ឺម៉ក ☐ ទូក កាណូត កប៉ាល់ សាឡាង
- លក្ខណៈសម្គាល់ ៖
  + ស្លាកលេខ______________ ម៉ាក______________ ឆ្នាំផលិត______________
  + លេខម៉ាស៊ីន______________ លេខតួ______________ លេខសាក់ស៊ី______________
  + កម្លាំង______________ ចំនួនភ្លៅ______________ ចំនួនស៊ីឡាំង______________ ទំហំស៊ីឡាំង______________

### III. ការគណនាប្រាក់ពន្ធ

| មូលដ្ឋានគិតពន្ធ | អត្រាពន្ធ ៤% | ប្រាក់ពន្ធ |
|---|---|---|
| | | |

ខ្ញុំបាទ-នាងខ្ញុំសូមធានាថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះពិតជាត្រឹមត្រូវ និងសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។

**សម្រាប់មន្ត្រីពន្ធដារ**

របៀបនៃការបង់ប្រាក់ : ☐សាច់ប្រាក់ ☐មូលប្បទានប័ត្រ ☐ផ្សេងៗ
ចំនួនទឹកប្រាក់ ..............................
បង់តាមបង្កាន់ដៃលេខ.................. ចុះថ្ងៃទី......./......./.......
លេខ.លិខិត គណនេយ្យកម្ម.................. ថ្ងៃទី......./......./.......
ឈ្មោះមន្ត្រីពន្ធដារ.................. ហត្ថលេខា ..................

ធ្វើនៅ______________, ថ្ងៃទី______ ខែ______ ឆ្នាំ______

ហត្ថលេខា ឬ ស្នាមមេដៃស្តាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
នាយកដ្ឋាន/សាខា.................

កាលបរិច្ឆេទទទួល

លេខអត្តសញ្ញាណកម្មសារពើពន្ធ

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |

# លិខិតប្រកាស
## ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ឆ្នាំ ........

### ក. ព័ត៌មានកម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដី

ឈ្មោះ ..........................................................................................
ឈ្មោះសហគ្រាស ..........................................................................................
អាសយដ្ឋាន ផ្ទះលេខ ................ ផ្លូវ ................ ក្រុម ............ ភូមិ ............................... ឃុំ/សង្កាត់ ..........................................
ក្រុង/ស្រុក/ខណ្ឌ .......................................... ខេត្ត/រាជធានី ..........................................................................
ទូរស័ព្ទ .................................................... ទូរសារ ......................................... សារអេឡិចត្រូនិក ..........................................

### ខ. អត្តសញ្ញាណដីធ្លី

១.ទីតាំងដីធ្លី

លេខឡូត៍-លេខក្បាលដី ..........................................................................................
ផ្លូវ ................ ក្រុម ...................... ភូមិ .............................. ឃុំ/សង្កាត់ ..........................................
ក្រុង/ស្រុក/ខណ្ឌ .................................................. ខេត្ត/រាជធានី ..........................................................

២.លក្ខណៈសម្គាល់

ប្រភេទដី ..........................................................................................
ទំហំដី៖ បណ្តោយ ............................................. ទទឹង .............................................. ផ្ទៃសរុប ..........................................
ឯកសារសម្គាល់ដីធ្លី៖ លេខ ...................................... ថ្ងៃទី ........ ខែ ........ ឆ្នាំ ........... ផ្តល់ដោយ ..........................................

### គ. ការគណនាប្រាក់ពន្ធ

| ពីឆ្នាំ-ដល់ឆ្នាំ | ផ្ទៃក្រឡាសរុប | ផ្ទៃក្រឡាកាត់ចេញ | ផ្ទៃក្រឡាជាប់ពន្ធ | តម្លៃដី/ម៉ែត្រក្រឡា | តម្លៃជាប់ពន្ធ | អត្រា | ចំនួនឆ្នាំ | ប្រាក់ពន្ធត្រូវបង់ |
|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ = (២-៣) | ៥ | ៦ = (៤x៥) | ៧ | ៨ | ៩ = (៦x៧x៨) |
| | | | | | | | | |

ខ្ញុំបាទ-នាងខ្ញុំសូមធានាថា ព័ត៌មានទាំងអស់នៅលើលិខិតប្រកាសនេះពិតជាត្រឹមត្រូវ និងសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ទាំងឡាយជាធរមាន ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ ។

### ឃ. ថែបមនបង់ប្រាក់

ធ្វើនៅ.......................... ថ្ងៃទី....... ខែ....... ឆ្នាំ

ហត្ថលេខា

| សម្រាប់មន្ត្រីពន្ធដារ | |
|---|---|
| បេឡា | |
| ប្រាក់ពន្ធ.................................... | ប្រាក់ពិន័យ.................................... |
| លេខបង្កាន់ដៃ.................................... | លេខបង្កាន់ដៃ.................................... |
| ថ្ងៃខែបង្កាន់ដៃ.................................... | ថ្ងៃខែបង្កាន់ដៃ.................................... |
| ☐ សាច់ប្រាក់ ☐ មូលប្បទានប័ត្រ ☐ បង្វែរ | |
| សរុប | |
| មន្ត្រីទទួលបន្ទុក .................................... កាលបរិច្ឆេទ .................................... | |